# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

ផ្នែកនេះ បង្ហាញពីសេដ្ឋកិច្ចនៃប្រទេសចំបង៧មួយចំនួនក្នុងពិភពលោក និង ប្រទេសកំពុងអភិវឌ្ឍន៍នៅអាស៊ីខាងកើត នៅត្រីមាសទី១ ឆ្នាំ២០០៨ ។

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០០៨ ផសស ពិតនៅសហរដ្ឋអាមេរិក កើន ២,៥% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ កំនើននេះឆ្លុះបញ្ចាំងនូវការរួមចំនែកជាវិជ្ជមានពីចំនាយប្រើប្រាស់ផ្ទាល់ខ្លួន និងចំនាយលើសេវាកម្ម ការនាំចេញទំនិញ និងសេវា ព្រមទាំង ចំនាយរដ្ឋាភិបាលសហព័ន្ធ ដែលកាត់កងវិញអស់មួយភាគដោយការរួមចំនែកអវិជ្ជមាន ពីវិនិយោគជាប់លាប់លើការស្នាក់នៅ ចំនាយប្រើប្រាស់ផ្ទាល់ខ្លួន ហើយនិង ចំនាយលើទំនិញប្រើបានយូរ ។ កំនើន ផសស ពិតនៅតំបន់អឺរ៉ូ ថយមកត្រឹម ២,២% ក្នុងរយៈមួយឆ្នាំ ធៀបនឹង ៣,០% ក្នុង រយៈមួយឆ្នាំដល់ត្រីមាសទី១ ឆ្នាំ២០០៧។ កំនើន ប្រចាំឆ្នាំនៅជប៉ុន គឺ ១,៣% ធៀបនឹង ២,០% នៅត្រីមាសទី៤ ឆ្នាំ២០០៧ និង ២,២% នៅត្រីមាសទី១ ឆ្នាំ២០០៧។

ផសស ពិតនៅចិន កើន ១០,៦% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំមុន ប៉ុន្តែវាថយចុះបន្តិច ធៀបនឹងអត្រា ១១,២% នៅត្រីមាសមុន ។ ការថយចុះកំនើនបន្តិចនេះ បណ្តាលពីការធ្លាក់ចុះការនាំចេញសុទ្ធរបស់ចិន។ កំនើន ផសស ពិតនៅកូរ៉េខាងត្បូង គឺ ៥,៧% ដែលដូចគ្នានឹងកំនើននៅត្រីមាសទី៤ ដែរ ប៉ុន្តែវាខ្ពស់ជាងកំនើននៅត្រីមាសទី១ឆ្នាំ២០០៧ ។ កំនើននេះបានជាចំបងពីកំនើនរឹងមាំយូរអង្វែងក្នុងវិស័យផលិតកម្ម និងកំនើនយ៉ាងខ្លាំងខាងទំនិញនាំចេញ ។ អត្រាកំនើន ផសស ពិតនៅតៃវ៉ាន់ និង កូរ៉េខាងត្បូង គឺ ៦,១% និង ៦,៨% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០៧។ ធៀបនឹងត្រីមាសមុន អត្រាកំនើននេះប្រែប្រួលតិចតួច ។

នៅម៉ាឡេស៊ី កំនើនពីមួយឆ្នាំទៅមួយឆ្នាំ គឺ ៧,១% ដែលប្រែប្រួលតិចតួចធៀបនឹងត្រីមាសមុន។ កំនើននេះបានពី កំនើនលេខពីរខ្ទង់នៃចំនាយប្រើប្រាស់ចុងក្រោយ (១១,៨%) ព្រមទាំង កំនើនយ៉ាងខ្លាំងក្នុងផលិតកម្ម (៦,៩%) និង សេវាកម្ម (៨,០%) ។ កំនើន ផសស ពិតនៅសិង្ហបុរី ក្នុងរយៈ១២ខែ គឺ ៧,២% ដែល ខ្ពស់ជាងកំនើន នៅត្រីមាសទី១ និង ទី៤ ឆ្នាំ២០០៧។ កំនើននេះបានពីការស្ទុះឡើងយ៉ាងខ្លាំងខាងផលិតកម្ម (១២,២%) សំនង់ (១៤,៧%) និងសេវាកម្មហិរញ្ញវត្ថុ (១៣,៤%)។ រីឯកំនើន ផសស ពិតនៅថៃ ទោះបីវាខ្ពស់ជាងត្រីមាសទី១ ឆ្នាំ២០០៧ ក្តី ប៉ុន្តែធៀបនឹងត្រីមាសមុនវាគ្មានកំនើនអ្វីជាដុំកំភួនទេ ។ កំនើនបានជាចំបងពីការរើបឡើងវិញខាងវិនិយោគ និង ចំណាយប្រើប្រាស់ដែលបានធ្លាក់ចុះយ៉ាងខ្លាំងនៅឆ្នាំ២០០៧ ។ កំនើននៃវិនិយោគជាប់លាប់ មាន ៥,៤% ចំណាយប្រើប្រាស់ឯកជនមាន ២,៦% និងការនាំចេញទំនិញនិងសេវា ៨,៧% ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្តូរប្រាក់

នៅត្រីមាសទី១ ឆ្នាំ២០០៨ ថ្លៃទំនិញប្រើប្រាស់នៅសហរដ្ឋអាមេរិក កើន ៤,១% (២,៤% នៅត្រីមាសដូចគ្នាឆ្នាំមុន) ដែលបណ្តាលមកពី កំនើនថ្លៃម្ហូបអាហារនិងភេសជ្ជៈ ផ្ទះ ការថែទាំសុខភាព ការអប់រំ និង ទូរគមនាគមន៍ ។ អតិផរណាក្នុងរយៈ១២ខែនៅតំបន់អឺរ៉ូ គឺ ៤,១% ដែលខ្ពស់ជាងនៅត្រីមាសទី១ និង ទី៤ ឆ្នាំ២០០៧ ។ កត្តាជំរុញកំនើននេះ គឺការឡើងថ្លៃយ៉ាងខ្ពស់នៃថាមពល ម្ហូបអាហារកែច្នៃ និងសេវាកម្ម។ នៅត្រីមាសទី១ ឆ្នាំ២០០៧ អតិផរណានៅជប៉ុនកើនដល់ ១,០% ដែលខ្ពស់ជាងនៅត្រីមាសទី១ និង ទី៤ ឆ្នាំ២០០៧ និងដែលផុសចេញពីការស្ទុះឡើងយ៉ាងខ្លាំងនៃថ្លៃថាមពល និង ម្ហូបអាហារ ។

នៅត្រីមាសទី១ ឆ្នាំ២០០៨ ក្នុងទីផ្សារប្តូរប្រាក់បរទេស ដុល្លារUS ឡើងថ្លៃទល់នឹង ប្រាក់យ៉ុនចិន និងប្រាក់វ៉ុនកូរ៉េខាងត្បូង ដោយប្តូរបាន ៨,១យ៉ុន/ដុល្លារUS និង ៩៥៥,៩វ៉ុន/ដុល្លារUS ប៉ុន្តែវាធ្លាក់ថ្លៃទល់នឹងប្រាក់យ៉េនជប៉ុន និង ប្រាក់បាតថៃ ដោយប្តូរបាន ១០៥,៣យ៉េន/ដុល្លារUS និង ៣០,៩បាត/ដុល្លារUS ។ អត្រាប្តូរប្រាក់អឺរ៉ូ-ដុល្លារ នៅថេរដដែលក្នុងអំឡុងត្រីមាសទី១ ឆ្នាំ២០០៨ នេះ ។

## ថ្លៃទំនិញប្រើប្រាស់នៅទីផ្សារពិភពលោក

នៅត្រីមាសទី១ ឆ្នាំ២០០៨ ថាមពល និងផលិតផលកសិកម្មជាច្រើន ដូចជា ពោត ប្រេងឆា អង្ករ និងសណ្តែកសៀង ជាដើម បន្តឡើងថ្លៃនៅទីផ្សារអន្តរជាតិ ។ ពោតឡើងថ្លៃ ២៦% ដល់ ១៩៨,៤ដុល្លារUS/តោន ហើយ សណ្តែកសៀងឡើងថ្លៃ ២២% ដល់ ៤៤៩,៦ដុល្លារUS/តោន ។ ប្រេងឆាឡើងថ្លៃដល់១០៤៨,៥ ដុល្លារUS /តោន ហើយ អង្ករថៃ 100% B ឡើងដល់ ៤៤៤,៤ដុល្លារUS/តោន ។ ម្យ៉ាងទៀត ប្រេងឆៅឡើងថ្លៃ ១៣%, សាំង ១៨%, និង ម៉ាស៊ូត ១១%។ ប្រេងឆៅលក់ថ្លៃ ៩៣,៨ដុល្លារUS/ធុង រីឯសាំង និងម៉ាស៊ូត លក់ថ្លៃ ៦៤,២សេន/លីត្រ និង ៧៤,០សេន/លីត្រ ៕

*រៀបរៀងដោយ លោក សាំង ច័ន្ទហង្ស*

**ឯកសារចេញផ្សាយប្រចាំខែរបស់វិទ្យាស្ថាន CDRI**

ឯកសារនេះ បង្ហាញជូនជារៀងរាល់ខែនូវសូចនាករសេដ្ឋកិច្ចសំខាន់ៗ ទាំងសំរាប់ប្រទេសកម្ពុជា និងបណ្តាប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជា ។ សូចនាករ មានជាអាទិ៍ ការនាំចេញ ចំនួនទេសចរចូលមកប្រទេសកម្ពុជា ប្រតិបត្តិការថវិកាជាតិ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ កំណើនផលិតផលក្នុងស្រុកសរុប ប្រាក់សន្សំក្នុងស្រុក អត្រាប្តូរប្រាក់រៀលជាមួយប្រាក់ដុល្លារ និងរូបិយវត្ថុប្រទេសជិតខាង ។



# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំណើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-០៨ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7 | 7.7 | 13.4 | 10.6 | 10.2 | - | 10.1 | 8.1 | 13.6 | - |
| ឥណ្ឌូនេស៊ី | 4.9 | 5.1 | 5.6 | 5.4 | 6.3 | - | 6.4 | 6.5 | 6.3 | 6.3 |
| ម៉ាឡេស៊ី | 5.4 | 7 | 5.2 | 5.9 | 6.3 | 5.3 | 5.7 | 6.7 | 7.3 | 7.1 |
| សិង្ហបុរី | 1.4 | 8.5 | 5.7 | 7.7 | 7.7 | 6.0 | 8.2 | 8.9 | 6.0 | 7.2 |
| ថៃ | 6.9 | 6 | 4.5 | 4.8 | 4.9 | 4.3 | 4.4 | 4.8 | 5.7 | 6.0 |
| វៀតណាម | 7 | 7.5 | 8.4 | 8.1 | 8.5 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 9.9 | 9.5 | 9.6 | 10.5 | 11.9 | 11.1 | 11.5 | 11.4 | 11.2 | 10.6 |
| ហុងកុង | 3.2 | 8.3 | 6.5 | 6.6 | 6.4 | 5.6 | 6.9 | 6.2 | 6.7 | 6.8 |
| កូរ៉េខាងត្បូង | 3 | 4.7 | 4.7 | 5.0 | 4.9 | 4.0 | 4.5 | 5.2 | 5.7 | 5.7 |
| តៃវ៉ាន់ | 3.1 | 5.7 | 4.1 | 4.6 | 5.2 | 4.1 | 5.07 | 6.9 | 6.4 | 6.1 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 0.5 | 1.8 | 1.5 | 2.7 | 2.9 | 3.0 | 2.5 | 2.7 | 2.2 | 2.2 |
| ជប៉ុន | 2.6 | 3.4 | 2.5 | 2.1 | 2.0 | 2.2 | 2.3 | 1.9 | 2.0 | 1.3 |
| សហរដ្ឋអាមេរិក | 3.1 | 4.4 | 3.7 | 3.3 | 2.2 | 1.5 | 3.8 | 4.9 | 2.5 | 2.5 |

*Sources: International Monetary Fund, Economist and countries' statistic offices*

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 1.2 | 4.0 | 5.8 | 4.7 | 10.5 | 3.0 | 4.6 | 6.0 | 9.6 | - |
| ឥណ្ឌូនេស៊ី | 8.3 | 8.3 | 10.5 | 13.4 | 6.4 | 6.4 | 6.0 | 6.5 | 6.7 | 7.6 |
| ម៉ាឡេស៊ី | 1.1 | 1.6 | 3.1 | 3.7 | 2.0 | 2.6 | 1.4 | 1.8 | 2.2 | 2.6 |
| សិង្ហបុរី | 0.5 | 1.7 | 0.5 | 1.0 | 2.1 | 0.5 | 1.0 | 2.7 | 4.1 | 6.6 |
| ថៃ | 1.8 | 2.7 | 4.5 | 4.7 | 2.2 | 2.4 | 1.9 | 1.7 | 2.9 | 5.0 |
| វៀតណាម | 3.1 | 7.8 | 8.2 | 7.7 | 8.3 | 6.6 | 7.4 | 8.6 | 10.7 | 16.4 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 1.2 | 3.9 | 1.8 | 1.5 | 4.8 | 2.6 | 3.6 | 6.1 | 6.6 | 8.0 |
| ហុងកុង | -2.6 | -0.4 | 1.1 | 2.2 | 2.0 | 1.7 | 1.3 | 1.6 | 3.5 | 4.6 |
| កូរ៉េខាងត្បូង | 3.5 | 3.5 | 2.8 | 2.4 | 2.5 | 2.0 | 2.4 | 2.3 | 3.3 | 3.7 |
| តៃវ៉ាន់ | -0.3 | 1.6 | 2.3 | 0.6 | 1.8 | 1.0 | 0.3 | 1.4 | 4.5 | 2.3 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ | 2.1 | 2.2 | 2.2 | 2.1 | 2.1 | 1.9 | 1.9 | 1.9 | 2.9 | 3.4 |
| ជប៉ុន | -0.3 | Nil | -0.3 | 0.5 | 0.1 | -0.1 | -0.1 | -0.1 | 0.5 | 1.0 |
| សហរដ្ឋអាមេរិក | 2.3 | 2.7 | 3.4 | 3.2 | 2.9 | 2.4 | 2.7 | 2.4 | 3.9 | 4.1 |

*Sources: International Monetary Fund, Economist and National Institute of Statistics*

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០៣-២០០៨ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3973 | 4016.3 | 4092.5 | 4103.2 | 4062.7 | 4046.7 | 4065.7 | 4078 | 4026 | 3995.3 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8577 | 8938 | 9705 | 9134 | 9419 | 9107 | 8968.3 | 9257.8 | 9240.2 | 9217 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.79 | 3.67 | 3.31 | 3.50 | 3.43 | 3.46 | 3.35 | 3.18 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.74 | 1.69 | 1.66 | 1.59 | 1.51 | 1.53 | 1.52 | 1.52 | 1.45 | 1.41 |
| ថៃ (បាត) | 41.5 | 40.2 | 40.2 | 37.9 | 32.22 | 33.9 | 32.5 | 31.4 | 33.87 | 30.95 |
| វៀតណាម (ដុង) | 15,510 | 15,777 | 15,859 | 15,994 | 16,030 | 16,356 | 16,125 | 16,105 | 16,030 | 16,125 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ុន) | 8.28 | 8.28 | 8.19 | 7.97 | 8.03 | 7.76 | 7.68 | 7.55 | 7.43 | 8.01 |
| ហុងកុង (ដុល្លារហុងកុង) | 7.78 | 7.79 | 7.78 | 7.77 | 7.8 | 7.81 | 7.82 | 7.81 | 7.77 | 7.79 |
| កូរ៉េខាងត្បូង (វ៉ុន) | 1192 | 1145 | 1024 | 955 | 929.04 | 939 | 929 | 927 | 921.23 | 955.89 |
| តៃវ៉ាន់ (ដុល្លារតៃវ៉ាន់-NT$) | 34.4 | 33.6 | 32.1 | 32.5 | 32.85 | 32.9 | 33.1 | 32.9 | 32.4 | 31.52 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ូ-១២ (អឺរ៉ូ) | 0.89 | 0.80 | 0.80 | 0.80 | 0.7 | 0.76 | 0.74 | 0.73 | 0.69 | 0.7 |
| ជប៉ុន (យ៉េន) | 115.9 | 108.2 | 110.2 | 116.4 | 117.8 | 119.4 | 120.8 | 117.7 | 113.07 | 105.3 |

*Sources: International Monetary Fund, Economist and National Bank of Cambodia*

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០៣-២០០៨ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2003 | 2004 | 2005 | 2006 | 2007 | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q1 | Q2 | Q3 | Q4 | Q1 |
| ពោត (US No. 2) - US ($/តោន) | 95.42 | 110.65 | 89.19 | 111.04 | 149.08 | 154.33 | 146.10 | 139.81 | 156.9 | 198.39 |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 402.03 | 427.47 | 381.32 | 433.85 | 707.68 | 552.06 | 691.44 | 745.86 | 841.39 | 1048.49 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 182.22 | 221.67 | 262.88 | 282.00 | 305.36 | 294.17 | 283.89 | 304.75 | 323.92 | 444.43 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 218.86 | 262.03 | 224.25 | 213.88 | 294.59 | 255.33 | 259.95 | 299.99 | 366.59 | 449.64 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.8 | 33.5 | 50.14 | 61.58 | 69.25 | 54.21 | 65.41 | 72.48 | 82.88 | 93.77 |
| សាំង - US Gulf Coast (សេន/លីត្រ) | 23 | 30.9 | 42.19 | 47.70 | 53.58 | 41.71 | 57.93 | 55.49 | 59.48 | 64.21 |
| ម៉ាស៊ូត (ស្ពាន់ធ័រតិច លេខ២) - US Gulf Coast (សេន/លីត្រ) | 21.63 | 29.48 | 44.35 | 51.35 | 55.51 | 45.61 | 53.90 | 56.62 | 66.54 | 73.99 |

*Sources: Food and Agriculture Organisation and US Energy Information Administration*

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

នៅត្រីមាសទី១ ឆ្នាំ២០០៨ ដំណើរការសេដ្ឋកិច្ចកម្ពុជាបានកើនឡើងយឺតៗ ។ ធៀបនឹងត្រីមាសមុន អនុមតិគំរោងវិនិយោគ និងសាងសង់ បានធ្លាក់ចុះយ៉ាងខ្លាំង រីឯពាណិជ្ជកម្មជាទូទៅបានកើនឡើង ។ ចំនួនភ្ញៀវមកដល់ កើនឡើងបន្តិច រីឯទំនិញប្រើប្រាស់នៅតែបន្តឡើងថ្លៃ ។

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

នៅត្រីមាសទី១ អនុមតិគំរោងវិនិយោគសរុបថយចុះ ៦៦% ធៀបនឹងឆ្នាំមុន មកត្រឹម ២៥៣,៤លានដុល្លារ ។ វិនិយោគលើវិស័យទាំងបី បានធ្លាក់ចុះយ៉ាងខ្លាំង ក្នុងនោះ វិនិយោគខាងកសិកម្មថយចុះ ៤៩% មកត្រឹម ៥២,៣លានដុល្លារ ខាងសេវាកម្មថយចុះ ៥២% មកត្រឹម ១៤៨,២លានដុល្លារ ហើយខាងឧស្សាហកម្មថយចុះយ៉ាងខ្លាំងអស់ ៨៤% មកត្រឹម ៥២,៩លានដុល្លារ ។ ជាទូទៅ ត្រីមាសទី១ គឺជាអំឡុងពេលដែលអនុមតិគំរោងវិនិយោគ កើនឡើង ។ ការធ្លាក់ចុះកំនើនសេដ្ឋកិច្ចសហរដ្ឋអាមេរិក បានជះឥទ្ធិពលជាខ្លាំងដល់ការធ្លាក់ចុះវិនិយោគនៅកម្ពុជា ។ បរិយាកាសនយោបាយមិនសូវច្បាស់លាស់ ដោយសារជិតដល់ពេលបោះឆ្នោតរដ្ឋសភាជាតិប្រហែលបានរួមចំណែកបង្កការធ្លាក់ចុះវិនិយោគនេះ ។ នៅត្រីមាសទី១ វិនិយោគគិតជាទ្រព្យសកម្មជាប់លាប់ដោយ អ្នកវិនិយោគចិន បានឈានមុខគេក្នុងឧស្សាហកម្មនៅកម្ពុជា (តំលៃវិនិយោគ ២១,១លានដុល្លារ) និងបន្ទាប់មកគឺ កូរ៉េខាងត្បូង (១១,៥លានដុល្លារ) ។ ក្នុងអនុមតិគំរោងឧស្សាហកម្ម គំរោងកាត់ដេរមាន ៤២,៣លានដុល្លារ រឺថយចុះ ៣៩% ធៀបនឹង ត្រីមាសមុន ។ វិនិយោគខាងសេវាកម្ម បានផ្តោតសំខាន់លើគំរោងទូរគមនាគមន៍ (២៤%នៃវិនិយោគខាងសេវាកម្មសរុប) ការសាងសង់កន្លែងលំហែកំសាន្ត និងផ្សារទំនើបធំៗ ។ គំរោងដែលបានស្នើឡើងក្នុងវិស័យទាំងបីនេះ នឹងប្រើពលករសរុប ៣១.៩៧១នាក់ ប្រសិនបើអនុវត្តបានពេញលេញទាំងអស់ ។

តំលៃអនុមតិគំរោងសាងសង់នៅភ្នំពេញថយចុះ ២០% ធៀបនឹងត្រីមាសមុនមកត្រឹម ១៣៧,៣លានដុល្លារ ។ អនុមតិគំរោងសាងសង់ផ្ទះល្វែងធ្លាក់ចុះ ៩,៤% មកត្រឹម ៥២,២លានដុល្លារ រីឯអនុមតិគំរោងសាងសង់ភូមិគ្រឹះ និងផ្ទះ កើនឡើងមួយជាពីរ ដល់ ៤៤,២លានដុល្លារ ។ តំលៃសរុបនៃអនុមតិគំរោងសាងសង់នេះ គឺសំរាប់ ១៥០គំរោង ។ ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០៧ អនុមតិគំរោងសាងសង់សរុបធ្លាក់ចុះ ១,៤% ក្នុងនេះ ខាងសំណង់ផ្ទះល្វែងធ្លាក់ចុះ ៤១% រីឯសំណង់ភូមិគ្រឹះ និងផ្ទះ កើនឡើងមួយជាបី ។

នៅត្រីមាសទី១ ឆ្នាំ២០០៨ ពាណិជ្ជកម្មកើនឡើងបន្តិច ធៀបនឹងត្រីមាសមុន ។ ឱនភាពពាណិជ្ជកម្មបានប្រសើរឡើង ដោយថយចុះពី ១៨៩,៣លានដុល្លារ មកត្រឹម ១៨០,៧លានដុល្លារ ។ ការនាំចេញរបស់កម្ពុជាដែលសឹងតែជាផលិតផលកាត់ដេរទាំងអស់ កើនឡើង ១,២% ដល់ ៨០៣,១លានដុល្លារ ។ ការនាំចេញខាងវិស័យឧស្សាហកម្ម កើនឡើង ៦,៤% ដល់ ៧៧៣,៤លានដុល្លារ រីឯការនាំចេញខាងវិស័យកសិកម្មថយចុះដែលក្នុងនេះ ការនាំចេញកៅស៊ូថយចុះ ៥២% មកត្រឹម ៧,០លានដុល្លារ ហើយការនាំចេញត្រីថយចុះ ២២% មកត្រឹម ០,៧លានដុល្លារ ។

ធៀបនឹងត្រីមាសមុន ការនាំចូលរបស់កម្ពុជានៅថេរត្រឹម ៩៨៣,៨លានដុល្លារ ។ ក្នុងនោះ តំលៃនាំចូលប្រេងកាតកើនឡើងបន្តិច ដល់ ៦០,០លានដុល្លារ រីឯការនាំចូលយានយន្ត និងគ្រឿងបន្លាស់កើន ៣២% ដល់ ១០២,៥លានដុល្លារ ។ ការនាំចូលសំភារៈសំនង់មានតំលៃ ៣៩,៧លានដុល្លារ រឺកើន ២២% ធៀបនឹងត្រីមាសមុន។ ការនាំចូលដែក កើន ៦៩% ដល់ ១៥,៨លានដុល្លារ រីឯការនាំចូលស៊ីម៉ង់ត៍ថយចុះ ៤,៥% មកត្រឹម ១១,៦លានដុល្លារ ។ ការនាំចូលគ្រឿងចក្រណាត់នៅថេរដដែល គឺ ១,៨លានដុល្លារ រីឯការនាំចូលសំលៀកបំពាក់ប្រើហើយថយចុះ ១៤% មកត្រឹម ១២,៩លានដុល្លារ ។ ការនាំចូលស្ករសកើនឡើង ២៣% ដល់ ២,៨លានដុល្លារ ហើយការនាំចូលស្រាបៀរកើន ៨,៦% ដល់ ៥,២លានដុល្លារ ។

នៅត្រីមាសទី១ ឆ្នាំ២០០៨ ភ្ញៀវមកដល់កម្ពុជាកើនឡើង ៦,០% ធៀបនឹងត្រីមាសមុន ដល់ ៦៤៤.២០៥នាក់ ។ ភ្ញៀវមកដល់តាមផ្លូវអាកាសកើន ៩,០% ដល់ ៤០២.០២៣នាក់ ក្នុងនេះអាកាសយានដ្ឋានអន្តរជាតិភ្នំពេញទទួលបាន ៤១% ។ ភ្ញៀវមកដល់តាមផ្លូវទឹកកើនយ៉ាងខ្លាំងបាន ៩២% ធៀបនឹងត្រីមាសមុន ដល់ ២៧.២៣២នាក់ ដែលបង្ហាញពីការពេញនិយមនៃដំណើរតាមផ្លូវទឹក ។ ភ្ញៀវមកដល់តាមផ្លូវគោក ថយចុះបន្តិចអស់ ៤.៥% មកត្រឹម ២១៤.៩៥០នាក់ ។ ភ្ញៀវមកសំរាកលំហែកើន ២១% ដល់ ៥៨០.១៦៩នាក់ រីឯភ្ញៀវមកធ្វើជំនួញថយចុះ ១១% មកត្រឹម ៣៧,៤៤៤នាក់ ។ ភ្ញៀវមកដល់ខេត្តសៀមរាបមាន ៥៥% នៃចំនួនភ្ញៀវសរុបមកកម្ពុជា រឺកើន ១២% ធៀបនឹងត្រីមាសមុន ។ កូរ៉េខាងត្បូងជាប្រទេសនាំមុខគេខាងភ្ញៀវធ្វើដំណើរមកកម្ពុជា (៩៧.៩៣៦នាក់) ហើយបន្ទាប់មក គឺ ជប៉ុន (៥៤.១៤៩នាក់) និង វៀតណាម (៥៣.៣៨៦នាក់) ។

## ហិរញ្ញវត្ថុសាធារណៈ

នៅត្រីមាសទី១ ឆ្នាំ២០០៨ រដ្ឋាភិបាលមានអតិរេកថវិកាចំនួន ១៣៥,០ពាន់លានរៀល ។ ចំនូលកើនឡើង ៤៥% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០៧ ដល់ ១១៩៤,១ពាន់លានរៀល ។ ចំនូលពន្ធកើន ៤០% ដល់ ៩៧៨,០ពាន់លានរៀល ក្នុងនេះ ចំនូលពន្ធក្នុងស្រុកមាន ៧១៩,៩ពាន់លានរៀល (រឺកើន ៤៨%) ហើយចំនូលពន្ធលើពាណិជ្ជកម្មអន្តរជាតិមាន ២៥៨,១ពាន់លានរៀល (រឺកើន ២២%) ។ ចំនូលមិនមែនពន្ធកើនឡើងច្រើនគួរសមបាន ៦៩% ដល់ ២១១,៤ពាន់លានរៀល ។ ចំនូលបានពីទ្រព្យសម្បត្តិ (ដូចជា ការជួលដីរដ្ឋ និងសហគ្រាសរដ្ឋ) ធ្លាក់ចុះយ៉ាងខ្លាំងអស់ ៩០% មកត្រឹម ២,៩ពាន់លានរៀល។ ចំនូលបានពីការលក់ទំនិញ និង សេវា (ដូចជា ការផ្តល់អាជ្ញាប័ណ្ណទីផ្សារនិងមិនមែនទីផ្សារ កំរៃរដ្ឋបាល កំរៃឈ្នូល និងពន្ធព្រលានយន្តហោះ) កើនឡើង ៣៤% ដល់ ១១៨,៩ពាន់លានរៀល។ ចំនូលមូលធនដែលជាប្រភពចំនូលគ្មានស្ថិរភាព បានកើនពីចំនួល 0 នៅត្រីមាសទី១ ឆ្នាំ២០០៧ ដល់ ៤,៨ពាន់លានរៀល នៅត្រីមាសទី១ ឆ្នាំ២០០៨ ។

នៅត្រីមាសទី១ ឆ្នាំ២០០៨ ចំនាយរបស់រដ្ឋាភិបាលកើនដល់ ១០៥៩,១ពាន់លានរៀល រឺកើន ១៥% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៧ ។ ចំនាយចរន្តដែលជាធម្មតាមានចំនួនច្រើនជាងគេបំផុត នៅថ្ងៃបិទបញ្ជីគណនី (ចុងត្រីមាសទី៤) កើន ១៦% ដល់ ៦៤៨,១ពាន់លានរៀល។ ចំនាយលើប្រាក់បៀវត្សរ៍កើន ២៦% ដល់ ២៥០,៧ពាន់លានរៀល និង ចំនាយមិនមែនប្រាក់បៀវត្សរ៍កើន ៥៦% ដល់ ២៦២,៨ពាន់លានរៀលដែលក្នុងនេះ ចំនាយលើការទិញ សំភារៈការិយាល័យ និងសំភារៈផ្គត់ផ្គង់ផ្សេងៗទៀត កើន ៩៣% ដល់ ៦៤,៥ពាន់លានរៀល ហើយ ចំនាយលើជំនួយសង្គមកិច្ច និងឧបត្ថម្ភធន កើន ៦៨% ដល់ ១០៤,៣ពាន់លានរៀល។ ចំនាយមូលធន មាន ៤១១,០ពាន់លានរៀល រឺកើន ១២% ធៀបនឹង ត្រីមាសដូចគ្នាឆ្នាំមុន។ ក្នុងចំនាយមូលធនសរុប មាន ៧៦% ដោះស្រាយដោយប្រភពទុនខាងក្រៅ ។

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## អតិផរណា និង អត្រាប្តូរប្រាក់បរទេស

នៅខែមករា ២០០៨ ថ្លៃទំនិញប្រើប្រាស់កើនឡើងយ៉ាងខ្លាំង ។ ការឡើងថ្លៃទំនិញអន្តរជាតិ បានប៉ះពាល់យ៉ាងខ្លាំងដល់កម្ពុជាដែលជាប្រទេសពឹងផ្អែកខ្លាំងលើការនាំចូល ។ នៅខែមករា ២០០៨ ថ្លៃទំនិញជារួម កើន ១៨,៧% ខ្ពស់ជាងកាលពីមួយឆ្នាំមុន ធៀបនឹងអត្រាឡើងថ្លៃ ១៦,៣% សំរាប់ខែធ្នូ ២០០៧ ។ ថ្លៃម្ហូបអាហារ និង ភេសជ្ជៈគ្មានជាតិស្រា កើន ២៤,២%។ ថ្លៃដឹកជញ្ជូនកើន ១០,២% ថ្លៃអប់រំកើន ៩,២% រីឯថ្លៃទូរគមនាគមន៍ធ្លាក់ចុះ ១២,៩% ។ ទន្ទឹមគ្នានេះ ថ្លៃសំលៀកបំពាក់ និងស្បែកជើង កើន ៨,៣%។ បំរែបំរួលថ្លៃទំនិញ និងសេវា រងឥទ្ធិពលយ៉ាងខ្លាំងពីថ្លៃប្រេងកាតក្នុងពិភពលោក ។ នៅត្រីមាសទី១ ឆ្នាំ២០០៨ សាំងលក់ថ្លៃជាមធ្យម ៤៥៨០រៀល/លីត្រ កើន ៤,៨% ធៀបនឹងត្រីមាសមុន ហើយម៉ាស៊ូតលក់ថ្លៃ ៣៩៨២ រៀល/លីត្រ កើន ៨,២%។

ទល់នឹងដុល្លារUS ប្រាក់រៀលឡើងថ្លៃ ០,៩% ធៀបនឹងត្រីមាសមុន ដោយប្តូរបាន ៣៩៩៥រៀល/ដុល្លារUS។ ទល់នឹងប្រាក់បាតថៃ និងប្រាក់ដុងវៀតណាម តំលៃប្រាក់រៀលនៅថេរ ដោយប្តូរបាន ១២៩,១រៀល/បាត និង ២៥,២រៀល/១០០ដុង។

## ការវិវត្តរូបិយវត្ថុ

នៅចុងខែមីនា ២០០៨ រូបិយវត្ថុទូទៅ (M2) រួមមាន ប្រាក់រៀលចរាចរ និងផ្ញើទុកក្នុងប្រព័ន្ធធនាគារ កើន ៥៥% ធៀបនឹងត្រីមាសទី១ ឆ្នាំ២០០៧ ដល់ ១២.០៤៧,២ពាន់លានរៀល។ ទន្ទឹមគ្នានេះ ប្រាក់រៀលចរាចរ កើន ៣៤% ដល់ ២៣២៤,០ពាន់លានរៀល ប្រាក់បញ្ញើជារៀលកើន ២៣% ដល់ ១៩១,០ពាន់លានរៀល ហើយប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៦១% ដល់ ៩៥៣២,៣ពាន់លានរៀល ។

កំនើនជាបន្តបន្ទាប់នៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធ បានបង្កើនបរិមាណសរុបនៃរូបិយវត្ថុទូទៅ (M2) ។ នៅខែមីនា ទ្រព្យសកម្មក្នុងស្រុកសុទ្ធក្នុងវិស័យធនាគារមានចំនួន ១១៣៦,៤ពាន់លានរៀល ដោយបានជាចំបងមកពីឥណទានក្នុងស្រុក ដែលកើនយ៉ាងខ្លាំងបាន ៩៥% ដល់ ៥៦៤៦,៩ពាន់លានរៀល ។ បំនុលផ្សេងទៀតក៏កើន ៤៣% ដល់ ៤៥១៣,៦ពាន់លានរៀលដែរ ។ ធាតុផ្សំនៃឥណទានក្នុងស្រុកដែលជាឥណទានរបស់រដ្ឋាភិបាល នៅថេរត្រឹម ២៩៦,៦ពាន់លានរៀល រីឯប្រាក់បញ្ញើរបស់រដ្ឋាភិបាលកើន ៨៣% ដល់ ២៦៩៧,០ពាន់លានរៀល ។ ឥណទានដល់វិស័យឯកជន កើន ៩៨% ធៀបនឹងត្រីមាសដូចគ្នា ឆ្នាំ២០០៧ ដល់ ៨៤៣៩,០ពាន់លានរៀល ។ ទ្រព្យសកម្មបរទេសសុទ្ធ កើន ៣៥% ដល់ ១០៩១,៩ពាន់លានរៀល ។ ការប្រមូលសាច់ប្រាក់ដាក់បញ្ចូលវិញទៅក្នុងសកម្មភាពសេដ្ឋកិច្ចសហគ្រាសធុនតូចនិងមធ្យម បានជួយជំរុញកំនើន តាមរយៈការផ្តល់លទ្ធភាពប្រើប្រាស់កំលាំងពលកម្មបានកាន់តែច្រើនថែមទៀត ៕

*រៀបរៀងដោយ*
*ផាន់ ដាលីស និង ប៊ុន ដូរីណា*


## Cambodia Development Review—2008 Subscription Rates

**Domestic Subscription (Individual)**

❐ English edition ($14) ❐ Khmer edition (5,000 riels) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges for processing local cheques). Total payment enclosed..........

**Domestic Subscription (Discount Price for Bulk Orders—Five Copies)**

❐ English edition ($60 for five copies) ❐ Khmer edition (20,000 riels for five copies) Payment by ❐ cash or ❐ local cheque (please add $2 to cover bank charges). Total payment enclosed..........

**International Subscription (Individual)**

| | | |
|---|---|---|
| ❐ Thailand, Laos, Vietnam | ❐ English edition ($25)* | ❐ Khmer edition ($15)* |
| ❐ Asia and Europe | ❐ English edition ($30)* | ❐ Khmer edition ($20)* |
| ❐ Americas and Africa | ❐ English edition ($35)* | ❐ Khmer edition ($25)* |

* Subscription includes postage. **Payment options:**

**1.** By Telegraphic Transfer – Please add $10 for bank charges to the above Total Cost.
Transfer to: Account Name: CDRI
Account Number: 133451
Bank Name: ANZ Royal Bank
Bank Address: Phnom Penh, Cambodia
Swift Code: ANZBKHPP
Receiver Correspondent Bank: JP Morgan Chase Manhattan Bank, New York
Swift Code: CHASUS33
CHIP UID 004966

**2.** By Cheque - Please add (overseas) $50 for bank charges to the above Total Cost. Please make Cheque payable to CDRI, attach it to this invoice and send in to Publications.

Title: ❐Mr ❐Ms ❐Dr ❐ Other ..........
First name: .......... Last name: .......... Position: ..........
Organisation / Company: ..........
Address (CCC Box if applicable): ..........
City / Province: .......... Country: ..........
Telephone: .......... Fax: ..........
e-mail: .......... ❐ Tick to receive regular information about CDRI publications via e-mail

To subscribe simply fill in this form and return it to CDRI with your payment. Do not send cash through the post.
Please inform the Publishing Department at CDRI if your contact details change.

# តាមដានសេដ្ឋកិច្ច ~ សន្ទស្សន៍សេដ្ឋកិច្ច

## តារាង១. គំរោងវិនិយោគឯកជនបានអនុម័ត ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 40.3 | 3.7 | 12.3 | 26.8 | 498.0 | 0.0 | 154.6 | 19.1 | 2.1 | 12.0 | 102.4 | 52.3 |
| ឧស្សាហកម្ម | 67.7 | 137.2 | 187.9 | 914.6 | 365.3 | 171.7 | 76.6 | 142.7 | 51.2 | 187.2 | 328.0 | 52.9 |
| *កាត់ដេរ* | *27.2* | *68.1* | *132.6* | *174.4* | *89.4* | *23.2* | *26.1* | *36.6* | *24.3* | *40.7* | *69.1* | *42.3* |
| សេវាកម្ម | 145.3 | 168.4 | 91.8 | 155.5 | 2939.1 | 94.5 | 740.7 | 335.7 | 138.0 | 957.7 | 311.1 | 148.2 |
| *សណ្ឋាគារ និងទេសចរណ៍* | *47.1* | *124.1* | *55.9* | *102.6* | *345.0* | *3.5* | *315.3* | *140.3* | *55.0* | *653.8* | *199.2* | *93.7S* |
| សរុប | 253.3 | 309.3 | 292.0 | 1096.9 | 3802.4 | 266.2 | 971.9 | 497.5 | 191.3 | 1156.9 | 741.5 | 253.4 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | -88.6 | 265.1 | -48.8 | -61.6 | 504.7 | -35.9 | -65.8 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 13.1 | 22.1 | -5.6 | 275.6 | 246.6 | -34.1 | 715.4 | 118.9 | 91.8 | 334.6 | -23.7 | -49.1 |

*Including expansion project approvals. Source: Cambodian Investment Board*

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញបានអនុម័ត ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 23.4 | 20.0 | 30.3 | 45.5 | 33.1 | 7.6 | 9.7 | 14.4 | 22.8 | 21.7 | 20.2 | 44.2 |
| ផ្ទះល្វែង | 179.9 | 91.6 | 167.6 | 204.2 | 213.3 | 67.1 | 54.5 | 88.9 | 33.2 | 117.5 | 57.6 | 52.2 |
| ផ្សេងៗ | 16.6 | 87.3 | 65.6 | 109.1 | 76.8 | 20.8 | 13.9 | 35.9 | 88.8 | 40.6 | 94.3 | 40.9 |
| សរុប | 219.9 | 198.9 | 263.5 | 358.8 | 323.3 | 95.5 | 78.2 | 139.2 | 144.7 | 179.7 | 172.2 | 137.3 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 16.1 | -18.1 | 78.0 | 3.9 | 24.2 | -4.2 | -20.2 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 12.0 | -9.5 | 32.5 | 36.2 | -9.9 | 24.8 | 8.9 | 106.5 | 76.0 | 88.2 | 120.2 | -1.4 |

*Source: Department of Cadastre and Geography of Phnom Penh municipality*

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 1453.2 | 1708.1 | 2108.1 | 2352.8 | 2799.9 | 807.5 | 736.7 | 707.8 | 705.0 | 890.8 | 793.4 | 803.1 |
| រួមមាន: សំលៀកបំពាក់ | 1355.8 | 1628.4 | 2027 | 2253.3 | 2698.9 | 782.0 | 716.0 | 677.5 | 688.2 | 846.1 | 727.1 | 773.4 |
| *- ទៅសហរដ្ឋអាមេរិក* | 943.4 | 1099.8 | 1270.9 | 1546.1 | 1847.1 | 522.8 | 483.2 | 499.1 | 451.2 | - | - | - |
| *- ទៅសហគមន៍អឺរ៉ុប* | 356.3 | 414.7 | 590.8 | 503.1 | 601.0 | 188.1 | 160.1 | 106.3 | 163.1 | - | - | - |
| *- ប្រទេសផ្សេងទៀត* | 56.1 | 113.8 | 165.3 | 204.1 | 250.7 | 71.0 | 72.8 | 72.0 | 73.8 | - | - | - |
| កសិកម្ម | 97.3 | 79.7 | 81.2 | 99.5 | 101.1 | 25.5 | 20.7 | 30.3 | 16.8 | - | - | - |
| *- កៅស៊ូ* | 29.7 | 35.1 | 38.3 | 36.7 | 41.4 | 13.6 | 10.2 | 8.4 | 6.9 | 11.7 | 14.6 | 7.0 |
| *- ឈើ* | 16.0 | 10.2 | 11.1 | 10.3 | 8.6 | 2.5 | 1.7 | 2.1 | 2.0 | 0.0 | 0.0 | 0.0 |
| *- ត្រី* | 4.3 | 2.8 | 10.6 | 10.1 | 5.9 | 1.6 | 1.4 | 0.7 | 0.4 | 1.2 | 0.9 | 0.7 |
| *- ផ្សេងៗ* | 47.4 | 31.6 | 21.3 | 42.6 | 45.1 | 7.7 | 7.5 | 19.0 | 7.5 | - | - | - |
| ការនាំចូលសរុប | 1707.8 | 1824.9 | 2149.0 | 2513.0 | 3057.0 | 784.3 | 807.1 | 790.9 | 911.6 | 924.5 | 982.7 | 983.8 |
| រួមមាន: ផលិតផលប្រេងកាត | 157.5 | 191.6 | 187.0 | 184.8 | 238.5 | 62.4 | 58.7 | 66.5 | 68.5 | 71.0 | 58.9 | 60.0 |
| សាំង | 25.9 | 33.2 | 30.2 | 40.2 | 49.6 | 13.1 | 13.2 | 15.7 | 20.2 | - | - | - |
| ម៉ាស៊ូត | 100.8 | 109.6 | 109.4 | 93.1 | 122.0 | 30.1 | 27.2 | 31.9 | 36.6 | - | - | - |
| សំភារៈសំណង់ | 12.9 | 80.8 | 95.3 | 134.7 | 154.4 | 42.5 | 35.8 | 44.1 | 31.6 | 34.9 | 32.5 | 39.7 |
| ផ្សេងៗ | 1568.2 | 1601.3 | 1914.0 | 2245 | 2731.0 | 698.5 | 731.0 | 699.2 | 807.5 | 818.6 | 891.3 | 884.1 |
| ជញ្ជីងពាណិជ្ជកម្ម | -254.6 | -116.8 | -40.9 | -160.1 | -257.1 | 23.2 | -70.4 | -83.1 | -208.1 | -30.7 | -189.3 | -180.7 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | - | - | - | - | - | -118.9 | -403.4 | 18.0 | 150.4 | -85.2 | -14.1 | 6.4 |
| ការនាំចេញសរុប | - | - | - | - | - | 23.7 | -8.8 | -3.9 | 0.4 | 26.4 | -10.9 | 1.2 |
| ការនាំចូលសរុប | - | - | - | - | - | 1.2 | 2.9 | -2.0 | 15.3 | 1.4 | 6.3 | 0.1 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំលៀកបំពាក់សរុប | 9.2 | -54.1 | -64.9 | 291.4 | 19.8 | -76.2 | 52.0 | -5.0 | 70.0 | -232.3 | 1.6 | 14.2 |
| ការនាំចេញសរុប | 14.6 | 17.5 | 23.4 | 11.6 | 19.0 | 10.6 | 14.3 | 17.3 | 8.0 | 10.3 | 7.7 | 13.5 |
| ការនាំចូលសរុប | 13.7 | 6.9 | 17.8 | 16.9 | 21.6 | 24.0 | 16.8 | 14.5 | 17.6 | 17.9 | 21.7 | 24.4 |

*Import data include tax-exempt imports. Sources: Customs and Excise Department, cited by NBC*

## តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | 2007 | | | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | ចំនួនអ្នកដំណើរ (ពាន់នាក់) | | | | | | | | | | | |
| តាមផ្លូវអាកាស | 523.0 | 456.0 | 626.1 | 856.5 | 1029.0 | 224.2 | 325.0 | 373.6 | 275.6 | 278.5 | 368.8 | 402.0 |
| តាមផ្លូវគោក និងទឹក | 263.5 | 245.0 | 428.9 | 565.1 | 672.9 | 146.4 | 191.0 | 177.2 | 148.9 | 153.3 | 239.2 | 242.2 |
| សរុប | 786.5 | 701.1 | 1055.0 | 1421.6 | 1701.9 | 370.6 | 516.0 | 550.8 | 424.5 | 431.8 | 608.0 | 644.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | 4.1 | 39.2 | 6.7 | -22.9 | 1.7 | 40.8 | 6.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | 30.0 | -10.9 | 50.5 | 34.7 | 19.7 | 14.7 | 24.1 | 20.4 | 19.2 | 16.5 | 17.8 | 17.0 |

*Source: Ministry of Tourism*

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ២០០២-០៨ (ពាន់លានរៀល)

| | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4* | Q1 |
| ចំណូលសរុប | 1744 | 1764 | 2126 | 2625 | 3259.2 | 732.2 | 1199.6 | 824.9 | 1016.8 | 1031.4 | 1146.1 | 1194.1 |
| ចំណូលចរន្ត | 1728 | 1733 | 2107 | 2474 | 2881.8 | 716.8 | 844.9 | 824.9 | 1012.4 | 1031.4 | 1141.6 | 1189.4 |
| ចំណូលពន្ធ | 1227 | 1220 | 1577 | 1911 | 2270.9 | 565.8 | 661.8 | 699.9 | 887.7 | 844.6 | 965.2 | 978.0 |
| ពន្ធគយ | 424 | 395 | 513 | 573 | 644.4 | 157.2 | 200.0 | - | - | - | - | - |
| ពន្ធក្នុងស្រុក | - | - | - | - | - | - | - | 487.9 | 642.1 | 584.8 | 661.8 | 719.9 |
| ពន្ធលើពាណិជ្ជកម្មក្រៅប្រទេស | - | - | - | - | - | - | - | 212.1 | 245.6 | 259.8 | 303.5 | 258.1 |
| ចំណូលមិនមែនពន្ធ | 501 | 513 | 530 | 563 | 610.9 | 151.0 | 183.1 | 125.0 | 124.7 | 186.9 | 176.4 | 211.4 |
| អាជីវកម្មព្រៃឈើ | 15 | 7 | 2 | 3 | 2 | 0.3 | 0.9 | - | - | - | - | - |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 123 | 120 | 94 | 123 | 83.1 | 11.7 | 30.0 | - | - | - | - | - |
| ចំណូលលើអចលនទ្រព្យ | - | - | - | - | - | - | - | 27.9 | 15.5 | 14.8 | 13.6 | 2.9 |
| លក់ទំនិញ និងសេវា | - | - | - | - | - | - | - | 88.8 | 93.0 | 100.1 | 124.3 | 118.9 |
| ចំណូលជាមូលធន | 16 | 31 | 19 | 152 | 377.4 | 15.4 | 354.7 | 0.0 | 4.5 | 0.0 | 4.5 | 4.8 |
| ចំណាយសរុប | 2948 | 2757 | 2932 | 3295 | 4174.7 | 1030.6 | 1191.9 | 923.9 | 1098.7 | 1126.1 | 1689.7 | 1059.1 |
| ចំណាយជាមូលធន | 1388 | 1171 | 1163 | 1328 | 1638.1 | 423.8 | 429.1 | 367.1 | 408.1 | 355.1 | 807.4 | 411.0 |
| ចំណាយចរន្ត | 1560 | 1586 | 1769 | 1967 | 2536.8 | 606.9 | 762.8 | 556.8 | 681.6 | 771.0 | 882.3 | 648.1 |
| អប់រំ និងសុខាភិបាល | 454 | 473 | 518 | 351 | 714.0 | 150.1 | 281.3 | - | - | - | - | - |
| ការពារជាតិ និងសន្តិសុខជាតិ | 438 | 411 | 423 | 451 | 520.2 | 155.3 | 170.1 | - | - | - | - | - |
| ក្រសួងផ្សេងៗទៀត | 668 | 702 | 828 | 1165 | 1302.5 | 301.5 | 311.4 | - | - | - | - | - |
| បៀវត្សរ៍ | 587 | 615 | 640 | 711 | 822.0 | 230.6 | 240.6 | 199.7 | 242.7 | 253.4 | 362.6 | 250.7 |
| ឧបត្ថម្ភធន និងជំនួយសង្គមកិច្ច | - | - | - | - | - | - | - | 61.9 | 184.0 | 115.0 | 194.2 | 104.3 |
| សមតុល្យជាទូទៅ | -1204 | -993 | -806 | -706 | -915.6 | -298.5 | 7.7 | -99.0 | -81.9 | -78.7 | -543.6 | 135.0 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 1249 | 886 | 864 | 1127 | 1360.7 | 335.2 | 376.2 | 344.0 | 313.9 | 290.3 | 741.5 | 299.2 |
| ហិរញ្ញប្បទានក្នុងស្រុក | -45 | 106 | 148 | -396 | -445.1 | -36.7 | -383.9 | -245.0 | -213.0 | -148.0 | -185.8 | -294.1 |

*Provisional for 2007. Source: MEF web site. * revised data*

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ អត្រាប្តូរប្រាក់ និងថ្លៃមាស (មធ្យមភាគតាមការិយបរិច្ឆេទ) ឆ្នាំ២០០២-០៨

| | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| (October-December 2006:100) | | | | | | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1* |
| | | | | | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | |
| ខេត្ត | - | - | - | - | - | - | - | 5.9 | 9.0 | 14.4 | 16.6 | 19.1 |
| ភ្នំពេញ | - | - | - | - | - | - | - | 4.7 | 5.8 | 7.7 | 12.4 | 16.8 |
| កម្ពុជា - ទំនិញគ្រប់ប្រភេទ | - | - | - | - | - | - | - | 5.7 | 8.5 | 11.9 | 15.9 | 18.7 |
| - ម្ហូបអាហារ និងភេសជ្ជៈគ្មានជាតិស្រា | - | - | - | - | - | - | - | 8.3 | 12.0 | 16.9 | 21.7 | 24.2 |
| - ដឹកជញ្ជូន | - | - | - | - | - | - | - | -3.4 | 1.1 | 2.0 | 5.3 | 10.2 |
| | | | | | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | |
| រៀលក្នុង ១ ដុល្លារ | 3912.1 | 3973.3 | 4016.3 | 4119.7 | 4119.0 | 4145.3 | 4129.4 | 4063.0 | 4075.4 | 4082.3 | 4030.1 | 3995.3 |
| រៀលក្នុង ១ បាតថៃ | 91.1 | 95.8 | 99.9 | 102.6 | 108.7 | 110.3 | 113.0 | 113.7 | 118.0 | 130.0 | 129.3 | 129.1 |
| រៀលក្នុង ១០០ ដុងវៀតណាម | 25.6 | 25.6 | 25.5 | 25.8 | 25.1 | 24.9 | 25.0 | 24.6 | 24.7 | 25.3 | 25.2 | 25.2 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 36.8 | 41.4 | 46.3 | 54.0 | 70.6 | 73.0 | 72.8 | 77.7 | 79.8 | 80.8 | 94.4 | 111.6 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 1521 | 1508 | 2088 | 2633 | 3140.0 | 3333 | 3250 | 3067 | 3100 | 3203 | 3679 | 3982 |
| ថ្លៃសាំង (រៀល/លីត្រ) | 2084 | 2150 | 2833 | 3442 | 4004.3 | 4200 | 4050 | 3750 | 3900 | 4002 | 4368 | 4580 |

*Sources: NIS, NBC & CDRI. *The data for consumer price index are available to January 2008.*

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ២០០២-០៨ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 2002 | 2003 | 2004 | 2005 | 2006 | | | 2007 | | | | 2008 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | Q3 | Q4 | Q1 |
| | | | | | | ពាន់លានរៀល | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 3737 | 4027 | 4797 | 5475 | 6682 | 6958 | 7224 | 8056 | 9048 | 9768 | 10735 | 10911 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -849 | -698 | -467 | -450 | -637 | -497 | -282 | -263 | -172 | 140 | 576 | 1136 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | -119 | -128 | -209 | -421 | -831 | -892 | -953 | -1176 | -1403 | -1547 | -1816 | -2400 |
| ឥណទានដល់ផ្នែកឯកជន | 1059 | 1337 | 1817 | 2394 | 2997 | 3288 | 3628 | 4066 | 4537 | 5376 | 6386 | 8050 |
| រូបិយវត្ថុទូទៅ M2 | 2888 | 3329 | 4330 | 5025 | 6045 | 6461 | 6942 | 7793 | 8876 | 9908 | 11311 | 12047 |
| រូបិយវត្ថុ M1 | 813 | 937 | 1153 | 1323 | 1512 | 1563 | 1658 | 1794 | 1748 | 1750 | 2052 | 2389 |
| រូបិយវត្ថុផ្សេងៗ | 2075 | 2392 | 3177 | 3702 | 4533 | 4898 | 5285 | 5999 | 7128 | 8158 | 9259 | 9658 |
| | | | | | | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | |
| រូបិយវត្ថុទូទៅ M2 | 31.0 | 15.2 | 30.0 | 16.1 | 30.6 | 29.4 | 38.2 | 36.5 | 46.8 | 53.4 | 62.9 | 54.5 |
| រូបិយវត្ថុ M1 | 33.5 | 15.3 | 23.0 | 14.7 | 24.4 | 22.2 | 25.3 | 23.9 | 15.7 | 12.0 | 23.8 | 33.2 |
| រូបិយវត្ថុផ្សេងៗ | 30.0 | 15.2 | 32.8 | 16.6 | 32.8 | 31.9 | 42.7 | 40.7 | 57.3 | 66.5 | 75.2 | 61.0 |

*Source: National Bank of Cambodia*

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ (ថ្លៃថេរ ខែវិច្ឆិកា ២០០០)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2003 | 2004 | 2005 | 2006 | 2007 | | | | 2007 | | |
| | វិច្ឆិកា | | | | វិច្ឆិកា | កុម្ភៈ | ឧសភា | សីហា | វិច្ឆិកា | ឧសភា | សីហា | វិច្ឆិកា |
| អ្នកធាក់ស៊ីក្លូ | 7594 | 8572 | 7614 | 7469 | 7393 | 6534 | 9245 | 7126 | 9393 | 8 | 18 | 27 |
| អ្នកលីសែង | 6233 | 6676 | 6895 | 6545 | 7045 | 6010 | 9798 | 7704 | 8852 | 33 | 47 | 26 |
| អ្នកលក់បន្លែតូចតាច | 5256 | 6532 | 6947 | 6000 | 6125 | 6125 | 8951 | 9116 | 8303 | 38 | 75 | 36 |
| អ្នករើសអេតចាយ | 2718 | 3944 | 4446 | 4416 | 3903 | 4530 | 5533 | 6038 | 5560 | 23 | 42 | 42 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2111 | 4932 | 4448 | 4426 | 4498 | 4078 | 5150 | 4193 | 4508 | 21 | -2 | 0 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4198 | 4177 | 4139 | 4365 | 4653 | 4126 | 4531 | 4561 | 4790 | 0 | 10 | 3 |
| កម្មកររោងចក្រកាត់ដេរ | 6701 | 9577 | 9277 | 8816 | 8957 | 11146 | 8347 | 9033 | 8207 | 6 | -2 | -8 |
| អ្នករត់ម៉ូតូឌុប | 8610 | 10092 | 9204 | 8201 | 8386 | 9144 | 12,886 | 8979 | 13,060 | 47 | 33 | 37 |
| កម្មករសំណង់គ្មានជំនាញ | 5399 | 6558 | 6382 | 5918 | 6028 | 5263 | 6075 | 5901 | 7550 | -5 | -2 | 43 |
| កម្មករសំណង់មានជំនាញ | 13,127 | 13,111 | 12,679 | 10,316 | 9466 | 10,215 | 11,892 | 11,723 | 10,956 | 21 | 24 | 7 |

** Waitresses' earnings do not include meals and accommodation provided by shop owners. Surveys on the revenue of waitresses, rice -field workers, garment workers, unskilled workers, motorcycle taxi drivers and construction workers began in February 2000. Source: CDRI*

## តពីទំព័រ ៧ ការសិក្សាពីឌីណាមិក ...

### កំណត់សំគាល់

១. បន្ថែមពីលើការកសាងសមត្ថភាពក្នុងការវិភាគ និងប្រមូលទិន្នន័យបែបបរិមាណនិងគុណភាព ជំនួយហិរញ្ញវត្ថុដែលទទួលបានពីការិយាល័យខាងភាពក្រីក្រនៃធនាគារពិភពលោក ក៏សំរាប់ចំណាយលើសកម្មភាពស្រាវជ្រាវសំខាន់ៗ ដូចជា ការរចនារៀបចំវិធីសាស្ត្រស្រាវជ្រាវ ការប្រមូល/បញ្ចូល/សំអាតទិន្នន័យបែបបរិមាណនិងគុណភាព និង ការបង្កើតឯកសារគោលនយោបាយស្ដីពី ផលប៉ះពាល់នៃការឡើងថ្លៃម្ហូបអាហារទៅលើសន្តិសុខស្បៀង ផលិតកម្មកសិកម្ម និង ការកាត់បន្ថយភាពក្រីក្រ ។ ប៉ុន្តែ CDRI និង ធនាគារពិភពលោក ត្រូវស្វែងរកជំនួយបន្ថែមសំរាប់ការចាត់ចែង និងវិភាគទិន្នន័យឱ្យកាន់តែទូលំទូលាយដើម្បីកសាងឯកសារគោលនយោបាយ ៤ ទៀត, បង្កើតរបាយការណ៍ជាភាសាខ្មែរ និងអង់គ្លេស, ធ្វើការផ្សព្វផ្សាយគោលនយោបាយ ព្រមទាំងការសន្ទនា ដែលមានប្រយោជន៍ ចំពោះអ្នកបង្កើតគោលនយោបាយ ។

២. ការពិភាក្សាលំអិត អាចស្វែងរកបានក្នុងឯកសារបច្ចេកទេសរបស់ CDRI "តើបទពិសោធន៏អ្វីខ្លះដែលយើងទទួលបានពីការសិក្សាពី ការចាកផុតពីភាពក្រីក្រ (MOPS)?" ៕

### ឯកសារយោង


Ballard, B. (ed.) (2007), *'We are living with worry all the time': A participatory poverty assessment of the Tonle Sap* (Phnom Penh: CDRI)

CDRI (2007a), *Cambodia Land Titling Rural Baseline Survey Report* (Phnom Penh: CDRI)

CDRI (2007b), *Pro-Poor Tourism in the Greater Mekong Sub-Region* (Phnom Penh: CDRI)

FitzGerald, I. & So Sovannarith (2007), *Moving Out Of Poverty: Trends in Community Well-Being and Household Mobility in Nine Cambodian Villages* (Phnom Penh: CDRI)

IRL (2007), *Perceptions of inequality in Cambodia: a survey* (Phnom Penh: Indochina Research Limited)

National Institute of Public Health, National Institute of Statistics & ORC Marcro (2006), *Cambodia Demographic and Health Survey 2005* (Calverton, MD: ORC Macro; Phnom Penh: National Institute of Statistics and Directorate General for Health)

National Institute of Statistics, Ministry of Planning, Ministry of Health & ORC Macro (2001), *Cambodia Demographic and Health Survey 2000* (Phnom Penh and Calerton, MD: NIS)

World Bank (2007), *Sharing Growth: Equity and Development in Cambodia: Equity and Development Report 2007* (Phnom Penh: World Bank)

World Bank (2006), *Cambodia: Halving Poverty by 2015?: Poverty Assessment 2006* (Phnom Penh: World Bank)


---

## តពីទំព័រ ១១ កម្មវិធីអត្តសញ្ញាណកម្ម ...

លើតំបន់ដែលមូលនិធិសមធមិសុខភាព កំពុងដំណើរ ។ ក្រសួងផែនការ ផ្ដល់ការបណ្ដុះបណ្ដាល និងការណែនាំដល់អង្គការទាំងនោះ ។

ក្រសួងផែនការមានទិសដៅអនុវត្តអត្តសញ្ញាណកម្មគ្រួសារក្រីក្រ នៅក្នុងតំបន់ជនបទទូទាំងប្រទេសកម្ពុជានៅប៉ុន្មានឆ្នាំខាងមុខ និងធ្វើបច្ចុប្បន្នភាពបញ្ជីគ្រួសារក្រីក្រជាប្រចាំ ហើយដើម្បីសម្រេចឱ្យបាននៅទិសដៅនេះ ក្រសួងផែនការត្រូវការនូវធនធានបន្ថែមទៀត ។ ក្នុងឆ្នាំ២០០៩ ក្រសួងផែនការ និងដៃគូអភិវឌ្ឍន៍របស់ខ្លួន នឹងបង្កើតកញ្ចប់ថវិកាជំនួយរួម (Multi-Donor Trust Fund) ដែលក្នុងក្របខ័ណ្ឌកញ្ចប់ជំនួយនេះ រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានា នឹងមានលទ្ធភាពរួមចំណែកក្នុង ការផ្ដល់ថវិកាសំរាប់គាំទ្រកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ។ កញ្ចប់ថវិកានេះ នឹងធានាចីរភាពនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការចែករំលែកទិន្នន័យជាមួយអ្នកផ្ដល់សេវា ទាំងស្ថាប័នរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីផ្ដល់នូវផលប្រយោជន៏ ដ៏ទូលំទូលាយដល់គ្រួសារក្រីក្រ ។

គោលបំណងសំខាន់មួយទៀតរបស់ក្រសួងផែនការ គឺសហការឱ្យបានជិតស្និទ្ធជាមួយក្រសួងមហាផ្ទៃ ដើម្បីសម្រេចឱ្យបាននូវការធ្វើសមាហរណកម្មអត្តសញ្ញាណកម្មគ្រួសារក្រីក្រ ទៅក្នុងក្របខ័ណ្ឌការងារក្រុមប្រឹក្សាឃុំ និងរចនាសម្ព័ន្ធគាំទ្រក្រុមប្រឹក្សាឃុំ (អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត និងក្រុមសម្របសម្រួលថ្នាក់ខេត្តនិងស្រុក) ។ ការធ្វើសមាហរណកម្មនេះ នឹងជួយជំរុញចីរភាពរយៈពេលវែងនៃអត្តសញ្ញាណកម្មគ្រួសារក្រីក្រ និងការប្រើប្រាស់ទិន្នន័យគ្រួសារក្រីក្រទូលំទូលាយដោយក្រុមប្រឹក្សាឃុំ ជាឧបករណ៏សំរាប់ការកសាងផែនការអភិវឌ្ឍន៏ឃុំ ។ ក្រសួងផែនការ នឹងស្វែងរកធនធានសម្រាប់គាំទ្រសកម្មភាពអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅថ្នាក់ឃុំនិងភូមិ ។ ធនធានទាំងនេះគួរតែផ្ដល់តាមរយៈមូលនិធិឃុំជាការប្រសើរ ។

កិច្ចការសំខាន់មួយទៀត គឺជំរុញការប្រើប្រាស់ទូលំទូលាយនូវទិន្នន័យដោយស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល កម្មវិធីនិងគម្រោងតាមវិស័យក៏ដូចជាក្រុមប្រឹក្សាឃុំ ជាឧបករណ៏សម្រាប់ផ្ដល់សេវានិងជំនួយដល់គ្រួសារក្រីក្រ ។ ក្រៅពីការរៀបចំសិក្ខាសាលាផ្សព្វផ្សាយទិន្នន័យគ្រួសារក្រីក្រនៅថ្នាក់ខេត្តនិងស្រុក កម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រនៃក្រសួងផែនការនឹងធ្វើការផ្សព្វផ្សាយនៅថ្នាក់ជាតិ ដើម្បីលើកកំពស់ការយល់ដឹងអំពីកម្មវិធីនិងដើម្បីផ្សព្វផ្សាយទិន្នន័យ ។ ក្រៅពីបទបង្ហាញដល់ក្រុមការងារបច្ចេកទេស និងវេទិកាផ្សេងទៀត សិក្ខាសាលាថ្នាក់ជាតិមួយដើម្បីចាប់ផ្ដើមប្រើប្រាស់នីតិវិធីថ្នាក់ជាតិជាផ្លូវការ គ្រោងធ្វើនៅត្រីមាសទី ៤ ឆ្នាំ២០០៨ ៕